# ការធ្វើមូលដ្ឋានីយកម្ម
# គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព
# មកក្នុងបរិការណ៍កម្ពុជា និងការធ្វើសមាហរណកម្មទៅក្នុង
# ផែនការជាតិ

ប៉ុច សុវណ្ណឌី
អគ្គនាយករងផែនការ ក្រសួង ផែនការ

រាជធានីភ្នំពេញ ថ្ងៃទី២៩ មិថុនា ឆ្នាំ២០១៨

# ចំណុចសំខាន់ៗ

១. វឌ្ឍនភាពនៃការធ្វើមូលដ្ឋានីយកម្ម គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព មកក្នុងបរិការណ៍ជាតិ

២. ការធ្វើសមាហរណកម្ម គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា នៅក្នុង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

៣. ប្រភពធនធានសម្រាប់ធ្វើឲ្យសម្រេចបាន គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា

៤. ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ

## ២. វឌ្ឍនភាពនៃការធ្វើមូលដ្ឋានីយកម្ម គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព មកក្នុងបរិការណ៍ជាតិ

- ចាប់ផ្តើមតាំងពីចុងឆ្នាំ២០១៥
- ផ្តោតការយកចិត្តទុកដាក់លើ ការកំណត់ជ្រើសរើស គោលដៅ ចំណុចដៅ និងសូចនាករ សម្រាប់ បរិការណ៍កម្ពុជា
- លទ្ធផលចុងក្រោយការការធ្វើមូលដ្ឋានីយកម្ម គឺផលិតចេញនូវឯកសារ ក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (គ.អ.ច.ក.)
- ឯកសារក្របខ័ណ្ឌ បែកចេញជាពីរផ្នែក៖
  - ➢ ផ្នែកទី១៖ ឯកសារគោលនិងផែនទីបង្ហាញផ្លូវ សម្រាប់ដាក់បញ្ចូល ទៅក្នុង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ
  - ➢ ផ្នែកទី២៖ គោលដៅ ចំណុចដៅ និងសូចនាករ នៃ គ.អ.ច.ក.

# ១. វឌ្ឍនភាពនៃការធ្វើមូលដ្ឋានីយកម្ម គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព មកក្នុងបរិការណ៍ជាតិ (ត)

ផ្នែកទី១៖ ឯកសារគោលនិងផែនទីបង្ហាញផ្លូវ សម្រាប់ដាក់បញ្ចូល ទៅក្នុងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ចែកចេញជា ៥ជំពូក៖

ជំពូកទី១៖ ក្របខ័ណ្ឌយុទ្ធសាស្រ្ត និង បរិការណ៍នៃការអភិវឌ្ឍ

ជំពូកទី២៖ បទពិសោធន៍ពីសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (គ.អ.ស.ក.)

ជំពូកទី៣៖ ក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា

ជំពូកទី៤៖ បញ្ហាប្រឈម ក្នុងការអនុវត្តន៍ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា

ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និង អនុសាសន៍

# ១. វឌ្ឍនភាពនៃធ្វើមូលដ្ឋានីយកម្ម គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព មកក្នុងបរិការណ៍ជាតិ (ត)

ផ្នែកទី២៖ គោលដៅ ចំណុចដៅ និងសូចនាករ ចែកចេញជា ពីរតារាង៖

តារាងទី១៖ សូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា តាម គោលដៅ និង ចំណុចដៅ នីមួយៗ (ស្ថាប័នទទួលខុសត្រូវ ប្រភពទិន្នន័យ វដ្តនៃទិន្នន័យ និយមន័យ វិធីសាស្ត្រក្នុងការគណនាតម្លៃចំណុចដៅ របស់សូចនាករនីមួយៗ)

តារាងទី២៖ តម្លៃគ្រាដើមនិងចំណុចដៅ នៃសូចនាករនីមួយៗ របស់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព

- គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា រួមមាន ១៧ + ១គោលដៅ ចំណុចដៅចំនួន ៩៨ និង សូចនាករចំនួន ២៤៨ (រួមទាំង សូចនាកររង)
  - ➢ គោលដៅ ១៨៖ បញ្ចប់ផលប៉ះពាល់ជាអវិជ្ជមានរបស់មីន/សំណល់ជាតិផ្ទុះពីសង្គ្រាម និងជំរុញការសង្គ្រោះជនរងគ្រោះ

## ២. ការធ្វើសមាហរណកម្ម គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា នៅក្នុង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

- ដើម្បីអនុវត្ត ត្រូវធ្វើសមាហរណកម្ម គ.អ.ច.ក. ទៅក្នុង៖
  - ផ.យ.អ.ជ.
  - ផែនការយុទ្ធសាស្ត្រតាមវិស័យ និង
  - ផែនការការនៅថ្នាក់ក្រោមជាតិ

# ២. ប្រភពធនធានសម្រាប់ធ្វើឲ្យសម្រេចបាន គោលដៅអភិវឌ្ឍន៍ ប្រកបដោយចីរភាពកម្ពុជា

- សម្រាប់គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (គ.អ.ស.ក.) ថវិកាសម្រាប់អនុវត្ត សកម្មភាពនានា ដើម្បីធ្វើឲ្យសម្រេចបាន គោលដៅ ចំណុចដៅ គាំទ្រដោយដៃគូអភិវឌ្ឍ
- ចំពោះ គ.អ.ច.ក. ថវិកាសម្រាប់អនុវត្តកម្មវិធី សកម្មភាព នានា ដើម្បីសម្រេចបាន គោលដៅ ចំណុចដៅ នឹងមានការចូលរួមភាគច្រើនពី ថវិកាជាតិ ប៉ុន្តែ នៅតែត្រូវការការ រួមចំណែកពី ដៃគូអភិវឌ្ឍ និងភាគីដែលមានចំណែកពាក់ព័ន្ធផ្សេងទៀត
- ជាទូទៅ ការវិភាជថវិកាសម្រាប់ធ្វើឲ្យសម្រេចបាន គ.អ.ច.ក. នឹងផ្អែកលើ ផ.យ.អ.ជ. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ (ផ.យ.អ.វ) និង ផែនការយុទ្ធសាស្ត្រថវិកា
- ថវិកាអាចមានការរួមចំណែកពី ផ្នែកឯកជន។

# ៥. ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ

ការតាមដានត្រួតពិនិត្យនិងវាតយតម្លៃ វឌ្ឍនភាពនៃការអនុវត្ត ផ.យ.អ.ជ. និង វឌ្ឍនភាពនៃការសម្រេចបាន គ.អ.ច.ក.

- ជំពូកទី៦ នៃ ផ.យ.អ.ជ. នឹងបង្ហាញពីការងារ តាមដានត្រួតពិនិត្យ និងវាយតម្លៃ ផ.ូ. អ.ជ. និង សូចនាករស្នូល សម្រាប់ ការងារនេះ
- តារាងទី២ នៃផ្នែកទី២ របស់ ក្របខ័ណ្ឌ គ.អ.ច.ក. នឹងត្រូវបានប្រើប្រាស់ សម្រាប់ តាមដានត្រួតពិនិត្យនិងវាយតម្លៃ វឌ្ឍនភាពនៃការសម្រេចបាន គ.អ.ច.ក.
- ការតាមដានត្រួតពិនិត្យនិងវាយតម្លៃនេះ នឹងត្រូវបានអនុវត្ត ជារៀងរាល់ ២ឆ្នាំម្តង ចាប់ផ្តើមពីឆ្នាំ២០១៩
- ប៉ុន្តែ ការងារនេះអាចប្រឈមនឹងការខ្វះខាត ទិន្នន័យគាំទ្រ

# សេចក្តីសន្និដ្ឋាន

- រាជរដ្ឋាភិបាលកម្ពុជា ប្តេជ្ញានឹងរួមចំណែកក្នុងការធ្វើឲ្យសម្រេចបាន របៀបវារៈឆ្នាំ២០៣០
- បទពិសោធន៍ល្អៗ ពីការអនុវត្ត និងធ្វើឲ្យសម្រេចបាន គ.អ.ស.ក. អាចនឹងយកមកអនុវត្ត សម្រាប់ធ្វើឲ្យសម្រេចបាន គ.អ.ច.ក.
- ត្រូវមានកិច្ចខិតខំប្រឹងប្រែងរួមគ្នា រវាង ស្ថាប័នរាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍ និង ភាគីដែលមាបចំណែកពាក់ព័ន្ធផ្សេងទៀត
- ថវិកាជាតិ នៅមានកម្រិត មិនអាចវិភាជទៅគ្រប់សកម្មភាព នៃ គ.អ.ច.ក.
- មានបញ្ហាប្រឈម ពី ទិន្នន័យគាំទ្រ ដល់ គ.អ.ច.ក
- ជឿជាក់ថា គ.អ.ច.ក. អាចនឹងសម្រេចបាន និងអាចរួមចំណែកធ្វើឲ្យសម្រេចបាន របៀបវារៈសាកល ឆ្នាំ២០៣០។

សូមអរគុណ !